# របាយការណ៍សង្ខេប
# ស្តីពី
# វឌ្ឍនភាព និង ទិសដៅការងារបន្តរបស់រដ្ឋបាលសង្កាត់រតនៈ ក្រុងបាត់ដំបង

ដោយលោក **យស់ យឿន** ចៅសង្កាត់រតនៈ

**អគុណសន្តិភាព !**

ជាបឋម ខ្ញុំបាទសូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាន នៅក្នុងសន្និសីទសារព័ត៌មាននាឱកាសនេះ ។ ក្នុងនាមក្រុមប្រឹក្សាសង្កាត់ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលដែលបានរៀបចំនូវសន្និសីទសារព័ត៌មាន ស្តីពី "វឌ្ឍនភាព និង ទិសដៅការងារបន្តរបស់រដ្ឋបាលសង្កាត់" ។ ព្រមទាំងសូមគោរពអគុណចំពោះ ឯកឧត្តម លោក ជំទាវ លោក លោកស្រី និង បងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលបានចូលរួមក្នុងសន្និសីទនេះ ។

ក្នុងនាមរដ្ឋបាលសង្កាត់ និង ប្រជាពលរដ្ឋក្នុងសង្កាត់រតនៈទាំងមូល ខ្ញុំបាទសូមយកឱកាសនេះសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិត របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវចក្ខុវិស័យ និងគោលនយោបាយដ៏ត្រឹមត្រូវ តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ជាពិសេសបានធ្វើឲ្យប្រទេសជាតិវិលមករកនូវសុខសន្តិភាពយ៉ាងពេញលេញបរិបូរណ៍។ ដែលស្ថានការណ៍នេះបានជួយជម្រុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខេត្ត ក៏ដូចជានៅតាមមូលដ្ឋានស្រុក ក្រុង ទាំងអស់ ក្នុងខេត្តបាត់ដំបង ។ ក្នុងនោះសង្កាត់រតនៈ ក្រុងបាត់ដំបង ក៏បានទទួលនូវផ្លែផ្កាយ៉ាងច្រើនរហូតមកដល់បច្ចុប្បន្ន ដោយបានប្រែក្លាយ ពី ស្ថានភាពលំបាក គ្មានការអភិវឌ្ឍន៍ មកជាតំបន់មានការអភិវឌ្ឍន៍លើគ្រប់វិស័យ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមអនុញ្ញាតគោរពរាយការណ៍ជូនដល់អង្គសន្និសីទ ជ្រាបថារដ្ឋបាលសង្កាត់ នៅក្នុងឆ្នាំ ២០២០ កន្លងមកនេះ បានខិតខំអនុវត្ត និងបំពេញការងារលើគ្រប់ផ្នែក ដើម្បីឆ្លើយតបនូវផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និង កម្មវិធីវិនិយោគ៣ឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សាសង្កាត់ រួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ ។ លើសមិទ្ធិផលដែលសម្រេចបាននេះ សង្កាត់រតនៈ នៅតែរក្សាបាននូវសន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម តាមរយៈការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ។

ក្រោមការណែនាំចង្អុលបង្ហាញ ពីក្រុមការងាររាជរដ្ឋាភិបាល រដ្ឋបាលខេត្ត រដ្ឋបាលក្រុងក្រោមម្លប់សន្តិភាព ជាក់ស្តែងរដ្ឋបាលសង្កាត់ ដែលបានកំណត់ពី ចក្ខុវិស័យ គោលបំណងគោលដៅ និង យុទ្ធសាស្ត្រនានា ដែលជាគម្រោង ឬ សកម្មភាព ជាអាទិភាពរបស់សង្កាត់ដែលជាមូលដ្ឋានសម្រាប់ ធ្វើសេចក្តីសំរេចចិត្តក្នុងការប្រើប្រាស់ធនធាន និងសក្តានុពលនានា

ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និង លើកកម្ពស់គុណភាពសេវា សំដៅឆ្លើយតបតម្រូវការ របស់ប្រជាពលរដ្ឋ និងចូលរួមចំណែក កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ជាបន្តខ្ញុំបាទសូមគោរពជម្រាបជូនពីស្ថានភាពទូទៅរបស់សង្កាត់រតនៈ ដូចខាងក្រោមៈ

**ក.ស្ថានភាពភូមិសាស្ត្រ**

សង្កាត់ រតនៈ ស្ថិតតាមបណ្តោយដងស្ទឹងសង្កែ មានព្រំប្រទល់ខាងត្បូងទល់នឹង ផ្លូវជាតិលេខ ៥ ចាប់ពីស្ពានថ្មចាស់ ទៅស្រុកសង្កែ , ខាងជើងទល់នឹង ភូមិ វត្តបាឡាត់ ឃុំ នរា ស្រុកសង្កែ ,ខាងលិចទល់នឹង ដងស្ទឹងសង្កែ , ខាងកើតទល់នឹង ភូមិ បេង ឃុំ អន្លង់វិល ស្រុកសង្កែ ។

- រដ្ឋបាលសង្កាត់មានក្រុមប្រឹក្សា ១១ រូប ស្រី ៣រូប មានភូមិ ចំណុះចំនួន ៨ និង អង្គភាពភូមិ ២៤ រូប ស្រី ១០ រូប ។
- មានផ្ទៃដីសរុប ៥០៧ ហិកតា ផ្ទៃដីបង្កបង្កើនផល ១៣០ ហិកតា ផ្ទៃដី ចំការ ២ហិកតា , ប្រជាពលរដ្ឋសរុប១១.៥៩៩ នាក់, ស្រី៥.៨៥៥នាក់ ,មានចំនួន២.៦៣០គ្រួសារ។
- ស្ថានភាពមុខរបរ ៖ កសិកម្ម ៨,២% , ផ្នែកសិប្បកម្ម ៤,១% ,ផ្នែកសេវាកម្ម ៧៤,៧% , មន្ត្រីរាជការ ១៣%។

សេដ្ឋកិច្ចរបស់សង្កាត់រតនៈ គឺពឹងផ្អែកលើ វិស័យពាណិជ្ជកម្ម វិនិយោគ និង វិស័យទេសចរណ៍ សេវាកម្ម ជាវិស័យសំខាន់ៗ ជាពិសេសសង្កាត់រតនៈ មានសក្តានុពល លើវិស័យអភិវឌ្ឍន៍ដីឡូតិ៍ និង បូរី ដែលទាក់ទាញអ្នកវិនិយោគ ជាច្រើនបានមកបណ្តាក់ទុន ជាការរួមចំណែក បង្កើនមុខរបររបស់ប្រជាជន ក្នុងមូលដ្ឋាន ។

**ខ.ការងារអភិវឌ្ឍន៍**

- **ផ្នែកអប់រំ**
  - មានវិទ្យាស្ថានគរុកោសល្យបាត់ដំបង ចំនួន ១
  - សកលវិទ្យាល័យឯកជន ចំនួន ២
  - សាលាបឋមសិក្សារដ្ឋ ចំនួន ៣
- **ផ្នែកកសិកម្ម ៖**
  - កសិដ្ឋានចិញ្ចឹមក្រពើ ៤ កន្លែង ,
  - កសិករ ធ្វើស្រែ ១៣០ ហិកតា , ចំការ ២ ហិកតា
- **ផ្នែកទេសចរណ៍ និង សេវាកម្ម ៖**
  - សួនច្បារសាធារណៈ មានបំពាក់ឧបករណ៍សម្រាប់ហាត់ប្រាណ ( សួនច្បារ **សម្តេចក្រឡាហោម ស ខេង** )
  - សណ្ឋាគារ ចំនួន ១៥ ទីតាំង ,មាន ៧៤២ បន្ទប់
  - ផ្ទះសំណាក់ ចំនួន ១៥ ទីតាំង ,មាន ៣០០ បន្ទប់

- ផ្ទះជួល ចំនួន ៩០ ទីតាំង ,មាន ៩០៦ បន្ទប់
- ភោជនីយដ្ឋាន ៨ ទីតាំង

- **ផ្នែកហេដ្ឋារចនាសម្ព័ន្ធ**
  - ផ្លូវបេតុង១ ខ្សែ ប្រវែង ៤៩៧ ម (ឧបត្ថម្ភដោយរដ្ឋបាលខេត្ត)
  - ដាក់លូរំដោះទឹក ប្រវែង ៦០ម (ឧបត្ថម្ភដោយរដ្ឋបាលខេត្ត)
  - ផ្លូវកៅស៊ូ បេទីម ប្រវែង ១.៥០០ម (ឧបត្ថម្ភដោយរដ្ឋបាលខេត្ត)
  - ជួសជុលពង្រីកផ្លូវនិងដាក់លូរំដោះទឹក ផ្លូវជាតិលេខ៥ ចាប់ពីចំណុចរូបសំណាក់លោកតាដំបងក្រញ៉ូង ដល់ ស្ពានថ្មថ្មី (សោហ៊ី) និង រៀបខឿនពុះចែកទ្រូងផ្លូវ និង បំពាក់បង្គោលភ្លើងបំភ្លឺផ្លូវ (ឧបត្ថម្ភដោយមន្ទីរសាធារណៈការ និង ដឹកជញ្ជូនខេត្តបាត់ដំបង)
  - ស្ថាបនាផ្លូវបេតុង ១ខ្សែ ប្រវែង៧០០ម និង ដាក់ប្រព័ន្ធលូរំដោះទឹក៣០០ម (ឧបត្ថម្ភដោយសប្បុរសជន )
  - ស្ថាបនាផ្លូវក្រាលថ្មម៉ិច ទំហំ ៤ម និង ដាក់លូរំដោះទឹក មានរហ្គា៤ ប្រវែង ១២៤ម (ឧបត្ថម្ភដោយសប្បុរសជន )
  - ស្ថាបនាផ្លូវបេតុង ៤ ខ្សែ ប្រវែង ៦០៦ ម ទទឹង ៤ម ចំណាយថវិកាអស់ **៣៧១.៤៤៩.៩៥០ រៀល** (មូលនិធិសង្កាត់ ឆ្នាំ ២០១៩-២០២០)
  - ស្ថាបនាលូរំដោះទឹក ចំនួន ៤ ខ្សែ ប្រវែង ៩៦០ម និង ផ្លូវក្រាលថ្មម៉ិចពីលើ ចំណាយថវិកាអស់ **២៨៥.៤៧៥.000 រៀល** ( មូលនិធិសង្កាត់ឆ្នាំ ២០១៩ - ២០២០)
  - រដ្ឋបាលសង្កាត់ បានធ្វើការសម្រុះសម្រួល និង បើកផ្លូវមួយខ្សែ ប្រវែង ២២៧ម ទទឹង ៥,៥ម បានសម្រេចជាស្ថាពរ អស់ថវិកា **៩.៣៧0.000៛** (ថវិកាសង្កាត់)
  - គម្រោងទន្លេសាប ១ ស្ថាបនាប្រពន្ធលូ និង ប្រឡាយ រំដោះទឹកភ្លៀង ទូទាំងសង្កាត់ រួចជាស្ថាពរ ប្រវែង **៦.៥០០ម** និង បន្តអនុវត្តគម្រោងទន្លេសាប ២ ស្ថាបនាប្រព័ន្ធលូរំដោះទឹកកខ្វក់ ទូទាំងសង្កាត់ ប្រវែង ១៩.៥៥៦ម ( ឧបត្ថម្ភគម្រោងដោយក្រសួងសាធារណៈការគាំទ្រដោយធនាគារ អភិវឌ្ឍន៍អាស៊ី ADB )

- **ផ្នែកសង្គមកិច្ច**
  - គាំទ្រសេវាសង្គម(គកនក) ចំណាយថវិកាអស់ **១២,៥00,000៛** ដោយៈ
    - ជួយសិស្សក្រីក្រ រៀននៅបឋមសិក្សាចំនួន ៧៥ នាក់ (សំលៀកបំពាក់សិស្ស, កាបូប, សំភារៈសិក្សាសម្រាប់រយៈពេល ១ ឆ្នាំ )
    - គ្រួសារមានផ្ទុកមេរោគ អេដស៍ និង របេង ចំនួន ២៥ គ្រួសារ
    - ឧបត្ថម្ភសម្ភារបង្គន់អនាម័យដល់គ្រួសារក្រីក្រ ៥ គ្រួសារ

- ផ្តល់ប័ណ្ណសមធម៌ជូនប្រជាពលរដ្ឋក្រីក្រ បានចំនួន ៨៣០ ប័ណ្ណ (ក្រ១=៥៤៨, ក្រ២= ២៨២)
- ផ្តល់កាតរីង ក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដល់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារក្រោមអាយុ ២ឆ្នាំ បានចំនួន ៨៧ នាក់

## គ-សកម្មភាពមនុស្សធម៌

- អាជ្ញាធរគ្រប់លំដាប់ថ្នាក់ បានខិតខំ យកចិត្តទុកដាក់ យកអស់កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ស្មារតី និង ថវិកា ចុះសួរសុខទុក្ខ ស្វែងយល់ពីបញ្ហា តម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានផ្ទាល់ ជួយឧបត្ថម្ភគាំទ្រដល់ប្រជាពលរដ្ឋក្រីក្រជួបការលំបាក ជនចាស់ជរា ស្ត្រី មេម៉ាយ ស្ត្រីមានផ្ទៃពោះ ជនពិការ គ្រួសារសព ដូចខាងក្រោម៖
  - គ្រួសារដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ១៩ ចំនួន ៥៩៩ គ្រួសារ ដោយប្រើប្រាស់ ៖ អង្ករ ,មី , ត្រីខ ,ទឹកត្រី ,ទឹកស៊ីអ៊ីវ សាប៊ូ ,ជេលលាងដៃ , អាល់កុល , ទឹកសុទ្ធ ម៉ាស់ ថ្នាំដុសធ្មេញ ,អំបិល ,ប៊ីចេង , ថវិកា និង ចាក់ផ្សាយសារណែនាំរបស់ក្រសួងសុខាភិបាល តាមមេក្រូចល័ត គ្រប់ខ្នងផ្ទះ ចំណាយថវិកាអស់សរុប **៦៣.៣៣៩.៧០០៛** ។
  - ប្រជាពលរដ្ឋដែលរងគ្រោះនិង ប៉ះពាល់ដោយសារទឹកជំនន់ស្ទឹងសង្កែ ចំនួន ១.១៣០ គ្រួសារ ដោយប្រើប្រាស់ អង្ករ, មី, ទឹកសុទ្ធ,ត្រីខ, ទឹកស៊ីអ៊ីវ, ទឹកត្រី ,អំបិល , ប្រេងកូឡា , ម្សៅសាប៊ូ ,ប្រេងឆា ,តង់កៅស៊ូ ,ស្ករស ,ទឹកដោះគោខាប់ , ភួយ,មុង , សារ៉ុង ,ក្រមារ, ស្រូវពូជ និង ថវិកា , ចំណាយថវិកាអស់សរុប **១៧៧.២១៧.៥០០៛** ។

## ឃ-ការផ្តល់សេវារដ្ឋបាល

- បំពេញលិខិតរដ្ឋបាលផ្សេងជូនប្រជាពលរដ្ឋបានចំនួន២.៧៧៧ ច្បាប់
- ផ្នែកអត្តសញ្ញាណកម្ម ៖
  - ផ្តល់សៀវភៅគ្រួសារ (ក៤) ៧៦ ក្បាល
  - ផ្តល់សៀវភៅស្នាក់នៅ (ក២) ២២០ ក្បាល
  - ផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ២៣០ សន្លឹក
- ការងារអត្រានុកូលដ្ឋាន
  - ចុះបញ្ជីកំណើត បានចំនួន ២២៦ នាក់
  - ចុះបញ្ជីបញ្ជាក់កំណើត បានចំនួន ៣២៧ នាក់
  - ចុះបញ្ជីមរណៈភាព បានចំនួន ៨១ នាក់
  - ចុះបញ្ជីអាពាហ៍ពិពាហ៍ បានចំនួន ១៧៥ គូ

## ង-ការងារសន្តិសុខ សណ្តាប់ធ្នាប់

- ដោះស្រាយ និង សម្របសម្រួលទំនាស់នានា បានចំនួន ១៥ ករណី

- នគរបាលប៉ុស្ដិ៍សហការបង្រ្កាបគ្រឿងញៀន ១ ករណី ឃាត់ខ្លួនជនសង្ស័យ ២ នាក់ ស្រី ១ នាក់ ដកហូតវត្ថុតាង មាន ម៉ាទឹកកក ៣០ កូនចង់តូច ,ថ្នាំយ៉ាម៉ាផ្កាឈូក ៤ គ្រាប់ ។
- ការធ្វើអត្តឃាដ ៖ កើតមានឡើងចំនួន១ ករណី (ព្រះសង្ឃ០១អង្គ គង់នៅវត្ត កណ្ដាល ដុត ខ្លួនឯង សុគត )។
- គ្រោះទឹកជំនន់៖ កើតមាន០១លើក បណ្ដាលអោយលិចផ្ទះប្រជាពលរដ្ឋចំនួន ៧៤៦ ខ្នងផ្ទះ ។
- ការទប់ស្កាត់សំណង់ខុសច្បាប់
- ការពង្រឹងប៉ុស្ដិ៍រដ្ឋបាលដឹកនាំប្រជាការពារ រៀបចំសណ្ដាប់ធ្នាប់តាមសួនសាធារណៈ មាត់ស្ទឹងសង្កែ និង ការងារបង្ការទប់ស្កាត់ ការប្រើប្រាស់ និងជួញដូរគ្រឿងញៀន ។
- រដ្ឋបាលសង្កាត់រតនៈ បានរៀបចំប្រជុំ ពិភាក្សាការងារភូមិ ឃុំ មានសុវត្ថិភាព ជាមួយ អាជីវករក្នុងសង្កាត់ដើម្បីស្វែងរកមូលនិធិគាំទ្រ ប្រជាការពារសង្កាត់ ។
- ឧបត្ថម្ភប្រជាការពារសង្កាត់ ប្រចាំខែចំនួន ១១នាក់ សម្រាប់ឆ្នាំ ២០២០ អស់ថវិកា ៣០.០០០.០០០៛ (ថវិកាបានមកពីការចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រចាំខែ) ។
- ឧបត្ថម្ភសំលៀកបំពាក់សម្ភារៈបរិក្ខាដល់ប្រជាការពារសង្កាត់អស់ថវិកា៥.៩៤០.០០០៛ (ថវិកាមូលនិធិសង្កាត់)

## ច-ទិសដៅការងារបន្ត

- បន្តការយកចិត្តទុកដាក់បម្រើសេវារដ្ឋបាលជូនប្រជាពលរដ្ឋអោយបានឆាប់រហ័ស ប្រកបដោយបរិយាប័ន ។
- បន្តខិតខំពង្រឹងកំលាំងនគរបាលប៉ុស្ដិ៍ និង ប្រជាការពារ ដើម្បីអនុវត្តគោលយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព អោយបានល្អ ។
- ផ្សព្វផ្សាយ និង ផ្ដល់ឳកាស អោយប្រជាពលរដ្ឋ យល់ដឹង អំពីច្បាប់ និង លិខិត បទដ្ឋាននានា គោលការណែនាំ បញ្ជ្រាបចំណេះដឹង ក្នុងការបង្កើតមុខរបរខ្នាតតូច ជូន ដល់ប្រជាពលរដ្ឋ
- លើកកម្ពស់ការយល់ដឹងពី ផែនការគណនេយ្យភាពសង្គម
- រៀបចំកម្មវិធីវិនិយោគបីឆ្នាំ រំកិល និង អនុវត្តគម្រោងមូលនិធិសង្កាត់ ឱ្យបានទាន់ ពេលវេលា
- បន្តផ្សព្វផ្សាយពីវិធានការការពារ ទប់ស្កាត់ជំងឺ ឆ្លងនានា ជាពិសេសជម្ងឺកូវីដ ១៩ តាម ការណែនាំរបស់ក្រសួងសុខាភិបាល និង របៀបរស់នៅស្អាត ហូបស្អាត និង ការធ្វើ អនាម័យបរិស្ថាន។
- ផ្សព្វផ្សាយ និង ណែនាំដល់ប្រជាពលរដ្ឋអោយចេះវេចខ្ចប់ទុកដាក់ សម្រាម និង កាក សំណល់ឱ្យបានត្រឹមត្រូវ ។
- ខិតខំគៀងគរដៃគូ អ្នកវិនិយោគ សប្បុរសជន ដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងសង្កាត់ ។